លេខ ១៣ ចេញផ្សាយថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែមិថុនា ឆ្នាំ២០២២

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## កិច្ចប្រជុំពិភាក្សាការងារជាមួយ សភាពាណិជ្ជកម្មកម្ពុជា (CCC)

នារសៀលថ្ងៃពុធ ២កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២២ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការីមួយចំនួន បានអញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាការងារជាមួយសភាពាណិជ្ជកម្មកម្ពុជា (CCC) ដោយមានការអញ្ជើញចូលរួមពី **ឯកឧត្តម ឧកញ៉ា ងួន ម៉េងតិច** អគ្គនាយកនៃសភាពាណិជ្ជកម្មកម្ពុជា និង **លោកឧកញ៉ា លឹម សុជាតិ** សមាជិកជ្រើសតាំងនៃសភាពាណិជ្ជកម្មកម្ពុជា ដែលជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **អ្នកឧកញ៉ា គិត ម៉េង** ប្រធានសភាពាណិជ្ជកម្មកម្ពុជា អមដោយលោកជំទាវ នួន ពេជ្រសុផល អគ្គនាយករងជាន់ខ្ពស់នៃសភាពាណិជ្ជកម្មកម្ពុជា ព្រមទាំងសហការី ដើម្បីពិនិត្យលទ្ធភាពក្នុង ការបង្កើតកិច្ចសហប្រតិបត្តិការរវាង **ន.ប.ធ.** និងសភាពាណិជ្ជកម្ម (CCC) ក្នុងគោលដៅជំរុញការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការចូលរួមក្នុងវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា។

## មាតិកា


- ❖ កិច្ចប្រជុំពិភាក្សាការងារជាមួយសភាពាណិជ្ជកម្មកម្ពុជា (CCC) ទំព័រទី១
- ❖ កិច្ចប្រជុំបូកសរុបការងារប្រចាំខែឧសភា និងទិសដៅការងារប្រចាំខែមិថុនា ឆ្នាំ២០២២ របស់នាយកដ្ឋានកិច្ចការទូទៅ ទំព័រទី២
- ❖ សិក្ខាសាលាផ្សព្វផ្សាយស្តីពី “កាតព្វកិច្ចរបស់បុគ្គលរាយការណ៍ និងទម្រង់របាយការណ៍បង្កកទ្រព្យសម្បត្តិ ដើម្បីប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ” ទំព័រទី២
- ❖ កិច្ចប្រជុំលើសមិទ្ធផលការងារសម្រេចបានប្រចាំខែឧសភា ឆ្នាំ២០២២ និងទិសដៅការងារសម្រាប់ខែបន្ទាប់របស់នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច ទំព័រទី៣
- ❖ ចូលរួមក្នុងកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មូលនិធិអភិវឌ្ឍសហគមន៍កសិកម្ម ទំព័រទី៣
- ❖ កិច្ចប្រជុំពិភាក្សាការងារជាមួយអង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** ពាក់ព័ន្ធនឹងដំណើរការនៃកម្មវិធីសវនកម្មសម្រាប់ឆ្នាំ២០២២ ទំព័រទី៣
- ❖ កិច្ចប្រជុំអន្តរនាយកដ្ឋាន ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងប្រកាស ស្តីពីការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច ទំព័រទី៣
- ❖ ចូលរួមសិក្ខាសាលាស្តីពី “តួនាទីនៃវិស័យធានារ៉ាប់រង និងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងសេដ្ឋកិច្ចឌីជីថលកម្ពុជា” ទំព័រទី៤
- ❖ វិបស្សនាផ្ទៃក្នុងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ (ថ្មី) ទំព័រទី៤
- ❖ កិច្ចប្រជុំអន្តរនាយកដ្ឋាន ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពី បែបបទ និងនីតិវិធីនៃការធ្វើអធិការកិច្ចបរធនបាលកិច្ច ទំព័រទី៤
- ❖ កិច្ចប្រជុំជាមួយថ្នាក់ដឹកនាំនិងតំណាងក្រុមហ៊ុន Phnom Penh Fintech Investment ទំព័រទី៥
- ❖ កិច្ចប្រជុំពិនិត្យវឌ្ឍនភាពការងារគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) ទំព័រទី៥
- ❖ សិក្ខាសាលាស្តីពី “កម្មវិធីចែករំលែកចំណេះដឹងរវាង **អ.ស.ហ.** និង OJK ទំព័រទី៥
- ❖ កិច្ចប្រជុំអន្តរនាយកដ្ឋាន ដើម្បីពិនិត្យ និងពិភាក្សាពីវឌ្ឍនភាពការងារពាក់ព័ន្ធនឹងគេហទំព័រ (Website) របស់ **ន.ប.ធ.** ទំព័រទី៦
- ❖ កិច្ចប្រជុំពិភាក្សាផ្ទៃក្នុងក្រសួងលើគម្រោងចំណូល-ចំណាយថវិកាឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទំព័រទី៦




អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia ☎ (855) 23 237 888






រូបភាពកិច្ចប្រជុំពិភាក្សាការងារជាមួយសភាពាណិជ្ជកម្មកម្ពុជា (CCC)

## កិច្ចប្រជុំបូកសរុបការងារប្រចាំខែឧសភា និងទិសដៅការងារប្រចាំខែមិថុនា ឆ្នាំ២០២២ របស់នាយកដ្ឋានកិច្ចការទូទៅ

នាព្រឹកថ្ងៃព្រហស្បតិ៍ ៣កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២២ **ឯកឧត្តម ណឺ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំបូកសរុបការងារប្រចាំខែឧសភា និងទិសដៅការងារប្រចាំខែមិថុនា ឆ្នាំ២០២២ របស់នាយកដ្ឋានកិច្ចការទូទៅ។ កិច្ចប្រជុំនេះមានការចូលរួមពីប្រធាននាយកដ្ឋាន, ប្រធានការិយាល័យ និងមន្ត្រីជំនាញនៃនាយកដ្ឋានកិច្ចការទូទៅទាំងអស់។ កិច្ចប្រជុំត្រូវបានបញ្ចប់ប្រកបដោយផ្លែផ្កា និងស្មារតីមោះមុតក្នុងការបំពេញការងារតាមផែនការខែបន្ទាប់។



រូបភាពកិច្ចប្រជុំបូកសរុបការងារប្រចាំខែឧសភា និងទិសដៅការងារប្រចាំខែមិថុនា ឆ្នាំ២០២២ របស់នាយកដ្ឋានកិច្ចការទូទៅ ដឹកនាំដោយឯកឧត្តម **ណឺ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី "កាតព្វកិច្ចរបស់បុគ្គលរាយការណ៍ និងទម្រង់របាយការណ៍បង្កកទ្រព្យសម្បត្តិ ដើម្បីប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ"

នាព្រឹកថ្ងៃអង្គារ ៨កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២២ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **ឯកឧត្តម នន ពិសិដ្ឋ** អគ្គនាយករង និងសហការី បានអញ្ជើញដឹកនាំ និងថ្លែងសុន្ទរកថាបើកសិក្ខាសាលាផ្សព្វផ្សាយស្តីពី "កាតព្វកិច្ចរបស់បុគ្គលរាយការណ៍និងទម្រង់របាយការណ៍បង្កកទ្រព្យសម្បត្តិ ដើម្បីប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ" ក្នុងគោលបំណងដើម្បីបញ្ជ្រាបការយល់ដឹងអំពីយន្តការស្ថាប័ន និងលិខិតបទដ្ឋានពាក់ព័ន្ធ ជាពិសេសកាតព្វកិច្ចរបស់បុគ្គលរាយ-កាណ៍ ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាបុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ច សរុបចំនួន ៣៨ នាក់។



រូបភាពសិក្ខាសាលាផ្សព្វផ្សាយស្តីពី "កាតព្វកិច្ចរបស់បុគ្គលរាយការណ៍និងទម្រង់របាយការណ៍បង្កកទ្រព្យសម្បត្តិ ដើម្បីប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ"។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំលើសមិទ្ធផលការងារសម្រេចបានប្រចាំខែឧសភា ឆ្នាំ២០២២ និងទិសដៅការងារសម្រាប់ខែបន្ទាប់របស់នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច

នារសៀលថ្ងៃអង្គារ ៨ កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២២ **ឯកឧត្តម ឈី សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំលើសមិទ្ធផលការងារសម្រេចបានប្រចាំខែឧសភា ឆ្នាំ២០២២ និងទិសដៅការងារសម្រាប់ខែបន្ទាប់របស់នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច។ កិច្ចប្រជុំនេះ មានការចូលរួមពីមន្ត្រីដឹកនាំការងារនាយកដ្ឋាន, អនុប្រធាននាយកដ្ឋាន, ប្រធានការិយាល័យ និងមន្ត្រីជំនាញនៃនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ចទាំងអស់។ កិច្ចប្រជុំនេះត្រូវបានបញ្ចប់ប្រកបដោយផ្លែផ្កា និងស្មារតីទទួលខុសត្រូវខ្ពស់។



រូបភាពកិច្ចប្រជុំលើសមិទ្ធផលការងារសម្រេចបានប្រចាំខែឧសភា ឆ្នាំ២០២២ និងទិសដៅការងារសម្រាប់ខែបន្ទាប់របស់នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច ដឹកនាំដោយ ឯកឧត្តម **ឈី សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច។

## ចូលរួមក្នុងកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មូលនិធិអភិវឌ្ឍសហគមន៍កសិកម្ម

នាព្រឹកថ្ងៃពុធ ៩កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២២ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មូលនិធិអភិវឌ្ឍសហគមន៍កសិកម្ម ដឹកនាំដោយ **ឯកឧត្តម វង់ សណ្ដាប់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



រូបភាពចូលរួមក្នុងកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មូលនិធិអភិវឌ្ឍសហគមន៍កសិកម្ម។

## កិច្ចប្រជុំពិភាក្សាការងារជាមួយអង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ. ពាក់ព័ន្ធនឹងដំណើរការនៃកម្មវិធីសវនកម្មសម្រាប់ឆ្នាំ២០២២

នាព្រឹកថ្ងៃអង្គារ ១៥កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយឯកឧត្តមអគ្គនាយករង, ប្រធាននាយកដ្ឋាន និងមន្ត្រីជំនាញនៃ **ន.ប.ធ.** បានជួបប្រជុំពិភាក្សាការងារជាមួយអង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារពាក់ព័ន្ធនឹងដំណើរការនៃកម្មវិធីសវនកម្មសម្រាប់ឆ្នាំ២០២២។



រូបភាពកិច្ចប្រជុំពិភាក្សាការងារជាមួយអង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** ពាក់ព័ន្ធនឹងដំណើរការនៃកម្មវិធីសវនកម្មសម្រាប់ឆ្នាំ២០២២។

## កិច្ចប្រជុំអន្តរនាយកដ្ឋាន ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពី ការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច

នារសៀលថ្ងៃអង្គារ ១៥កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំអន្តរនាយកដ្ឋាន ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពី ការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច។




រូបភាពកិច្ចប្រជុំអន្តរនាយកដ្ឋាន ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពី ការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច។

## ចូលរួមសិក្ខាសាលាស្តីពី "តួនាទីនៃវិស័យធានារ៉ាប់រង និងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងសេដ្ឋកិច្ចឌីជីថលកម្ពុជា"

នាព្រឹកថ្ងៃពុធ ១រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញចូលរួមសិក្ខាសាលាស្តីពី "តួនាទីនៃវិស័យធានារ៉ាប់រង និងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងសេដ្ឋកិច្ចឌីជីថលកម្ពុជា" ដែលបានប្រព្រឹត្តទៅនៅសណ្ឋាគារ សូហ្វីតែលភ្នំពេញភូគីត្រា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមការងាររៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា។




រូបភាពចូលរួមសិក្ខាសាលាស្តីពី "តួនាទីនៃវិស័យធានារ៉ាប់រង និងបច្ចេក-វិទ្យាហិរញ្ញវត្ថុក្នុងសេដ្ឋកិច្ចឌីជីថលកម្ពុជា"

## វិបស្សនាផ្ទៃក្នុងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ (ថ្មី)

នាព្រឹកថ្ងៃចន្ទ ៦រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសហការីបានចូលរួមវិបស្សនាផ្ទៃក្នុងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រព្រឹត្តទៅរយៈពេលបីថ្ងៃគឺនៅថ្ងៃទី២០, ២១ និង ២២ ខែមិថុនា ឆ្នាំ២០២២ ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ (ថ្មី) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈប្រព័ន្ធវីដេអូពីចម្ងាយ។



រូបភាពវិបស្សនាផ្ទៃក្នុងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ (ថ្មី)

## កិច្ចប្រជុំអន្តរនាយកដ្ឋាន ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពី បែបបទ និងនីតិវិធីនៃការធ្វើអធិការកិច្ចបរធនបាលកិច្ច

នារសៀលថ្ងៃចន្ទ ៦រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំអន្តរនាយកដ្ឋាន ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពី បែបបទ និងនីតិវិធីនៃការធ្វើអធិការកិច្ចបរធនបាលកិច្ច។



រូបភាពកិច្ចប្រជុំអន្តរនាយកដ្ឋាន ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពី បែបបទ និងនីតិវិធីនៃការធ្វើអធិការកិច្ចបរធនបាលកិច្ច។

## កិច្ចប្រជុំជាមួយថ្នាក់ដឹកនាំនិងតំណាងក្រុមហ៊ុន Phnom Penh Fintech Investment

នាព្រឹកថ្ងៃព្រហស្បតិ៍ ៩រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានជួបប្រជុំតាមប្រព័ន្ធអនឡាញជាមួយថ្នាក់ដឹកនាំនិងតំណាងក្រុមហ៊ុន Phnom Penh Fintech Investment ដើម្បីផ្លាស់ប្តូរ និងចែករំលែកបទពិសោធន៍ទៅវិញទៅមកអំពីវិស័យបរធនបាលកិច្ច ជាពិសេសផ្តោតលើប្រព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech) នៅក្នុងវិស័យបរធនបាលកិច្ចនៅកម្ពុជា។



រូបភាព **ឯកឧត្តម សុខ ដារ៉ា** អមដោយសហការី ក្នុងកិច្ចប្រជុំតាមប្រព័ន្ធអនឡាញជាមួយថ្នាក់ដឹកនាំនិងតំណាងក្រុមហ៊ុន Phnom Penh Fintech Investment

## កិច្ចប្រជុំពិនិត្យវឌ្ឍនភាពការងារគម្រោងប្រកួតប្រជែងខ្សែច្រវ៉ាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)

នារសៀលថ្ងៃព្រហស្បតិ៍ ៩រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២ អង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវ៉ាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) សម្រាប់ Output 1 បានរៀបចំកិច្ចប្រជុំជាមួយអ្នកជំនាញការទាំងក្នុងស្រុក និងបរទេស ក្រោមការដឹកនាំរបស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជានាយកគម្រោង ACSEP សម្រាប់ Output 1 អមដោយ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាប្រធានគម្រោង ACSEP សម្រាប់ Output 1 ព្រមទាំងប្រធានផ្នែកទាំង៤ និងសហការីក្នុងក្របខណ្ឌគម្រោង ACSEP សម្រាប់ Output 1 ដើម្បីពិនិត្យវឌ្ឍនភាពការងារគម្រោង ព្រមទាំងលើកទិសដៅការងារបន្ត ក៏ដូចជាណែនាំការងារបន្ថែម ដោយមានការចូលរួមដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញ។



រូបភាពកិច្ចប្រជុំពិនិត្យវឌ្ឍនភាពការងារគម្រោងប្រកួតប្រជែងខ្សែច្រវ៉ាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)

## សិក្ខាសាលាស្តីពី "កម្មវិធីចែករំលែកចំណេះដឹងរវាង អ.ស.ហ. និង OJK"

នាព្រឹកថ្ងៃចន្ទ ១៣រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញចូលរួមសិក្ខាសាលាស្តីពី "កម្មវិធីចែករំលែកចំណេះដឹងរវាងអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ជាមួយនឹងអាជ្ញាធរសេវា

ហិរញ្ញវត្ថុមិនមែនធនាគារនៃប្រទេសឥណ្ឌូនេស៊ី (OJK)" ដែលបានប្រព្រឹត្តទៅនៅសណ្ឋាគារ រ៉ូសវូដ ភ្នំពេញ ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.**។




រូបភាពសិក្ខាសាលាស្តីពី "កម្មវិធីចែករំលែកចំណេះដឹងរវាង **អ.ស.ហ.** និង OJK។

## កិច្ចប្រជុំអន្តរនាយកដ្ឋាន ដើម្បីពិនិត្យ និងពិភាក្សាពីវឌ្ឍនភាពការងារពាក់ព័ន្ធនឹងគេហទំព័រ (Website) របស់ ន.ប.ធ.

នាព្រឹកថ្ងៃអង្គារ ១៤រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២ **ឯកឧត្តម ណឺ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** បានដឹកនាំកិច្ចប្រជុំអន្តរនាយកដ្ឋាន ដើម្បីពិនិត្យ និងពិភាក្សាពីវឌ្ឍនភាពការងារពាក់ព័ន្ធនឹងគេហទំព័រ (Website) របស់ **ន.ប.ធ.** មុននឹងដាក់ឱ្យដំណើរការសាកល្បងជាផ្លូវការ។ កិច្ចប្រជុំនេះ មានការចូលរួមពីថ្នាក់ដឹកនាំ និងតំណាងមកពីនាយកដ្ឋានចំណុះឱ្យ **ន.ប.ធ.** ព្រមទាំងមានការធ្វើបទបង្ហាញដោយមន្ត្រីជំនាញការិយាល័យគ្រប់គ្រងព័ត៌មានវិទ្យាអំពីដំណើរការ និងវឌ្ឍនភាពការងារពាក់ព័ន្ធនឹង Website របស់ **ន.ប.ធ.** ផងដែរ។



រូបភាពកិច្ចប្រជុំអន្តរនាយកដ្ឋាន ដើម្បីពិនិត្យ និងពិភាក្សាពីវឌ្ឍនភាពការងារពាក់ព័ន្ធនឹងគេហទំព័រ (Website) របស់ **ន.ប.ធ.** ។

## កិច្ចប្រជុំពិភាក្សាផ្ទៃក្នុងក្រសួងលើគម្រោងចំណូល-ចំណាយថវិកាឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

នាព្រឹកថ្ងៃពុធ ១កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ **លោក ឃុន វាសនា** ប្រធាននាយកដ្ឋានកិច្ចទូទៅ តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានចូលរួមកិច្ចប្រជុំពិភាក្សាផ្ទៃក្នុងក្រសួងលើគម្រោងចំណូល-ចំណាយថវិកាឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានប្រព្រឹត្តទៅនៅសណ្ឋាគារឆ្នេរសុខា ខេត្តព្រះសីហនុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារថវិកាកម្រិតថ្នាក់ដឹកនាំអង្គភាពថវិកា។



រូបភាពកិច្ចប្រជុំពិភាក្សាផ្ទៃក្នុងក្រសួងលើគម្រោងចំណូល-ចំណាយថវិកាឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888